# អច្ឆរិយវត្ថុទាំង៧នៅលើលោក

## LES 7 MERVEILLES DU MONDE

Puisque cette année est une année marquante pour le Cambodge, l'entrée du Temple de Preah Vihear au patrimoine mondial de l'Unesco, nous découvrons dans l'article suivant les monuments historiques qui sont classés dans les 7 merveilles du monde pour les monuments qui ont été construits dans l'antiquité.

អច្ឆរិយវត្ថុពិភពលោក ជាសំនួនវោហាស័ព្ទដែលប្រើប្រាស់សម្រាប់សំដៅទៅលើសំណង់ទាំង ៧ ដែលមនុស្សជំនាន់ដើម (សម័យមុន គ្រិស្តសករាជ) ចាត់ទុកថាជាសមិទ្ធិដ៏អស្ចារ្យជាងគេខាងផ្នែកចម្លាក់ ក៏ដូចជាខាងផ្នែកស្ថាបត្យកម្ម។ សញ្ញាណនៃអច្ឆរិយវត្ថុពិភពលោកកើតមានឡើងជាលើកតំបូងនៅក្នុង De septem orbis miraculis ដែលផ្តល់ឱ្យជាទូទៅចំពោះ Philon de Byzance (នៅសតវត្សទី ៣មុនគ្រិស្តសករាជ)។ បញ្ជីរាយឈ្មោះរបស់ បូជនីយដ្ឋានល្បីល្បាញទាំងនោះរួមមាន : វិមានតម្កល់សពរបស់ Halicarnasse ពីរ៉ាមីដកេអុប សើនអាឡិចសង់ឌ្រី រូបចម្លាក់ធំសម្បើមអស្ចារ្យ Rhodes សួនច្បារអាកាសបាប៊ីឡូន រូបចម្លាក់ Zeus Olympienនៅ Zeus Olympie និងចុងក្រោយនោះគឺវិហារ Artémis នៅ Éphèse។

បូជនីយដ្ឋានឈាបនកិច្ចដែលមានឈ្មោះថា វិមានតម្កល់សព Halicarnasse ត្រូវបានកសាងឡើងនៅពាក់កណ្តាលសតវត្សទី ៤ មុនគ្រិស្តសករាជនៅឆ្នាំប្រមាណជា (៣៧៧ ដល់ ៣៦៣) សម្រាប់ចៅហ្វាយក្រុង Carie។ ការកសាងត្រូវបានធ្វើឡើងក្រោមការគ្រប់គ្រងរបស់ Satyros និង Pythéos ដែលក៏ជាស្ថាបនិកវិហារអាតែណានៅព្រីយែមផងដែរ (Athéna à Priène)។ សំណង់នេះរួមមានទីលានរាបស្មើដ៏ទូលាយមួយដែលប្រើប្រាស់សម្រាប់ជាគ្រិះសរសរស្តំលំអរជាជួររបស់វិមាន ព្រមទាំងបល្ល័ង្កសឹងជារាងបួនជ្រុងស្មើសង់នៅលើជើងតាងខ្ពស់មួយ និងលម្អដោយពីរ៉ាមីដជាថ្នាក់ៗ។ ចំណែកខាងចម្លាក់ឯណោះវិញ ចម្លាក់ក្រឡោត ក៏ដូចជាចម្លាក់លៀនបង្កើតបានជាក្បូរក្បាច់រចនាយ៉ាងច្រើនលម្អកំពូលតំបូល លម្អនៅតាមចន្លោះពីសរសរមួយទៅមួយ លម្អទីលានរាបស្មើ ព្រមទាំងលម្អនៅតាមគែមជើងតាងដ៏ល្បីល្បាញនោះ។ ជាងចម្លាក់ល្បីៗបួនរូបនៅសតវត្សទី ៤មុនគ្រិស្តសករាជ រួមមាន Timothéos, Scopas, Bryaxis និង Léocharès បានចូលរួមនៅក្នុងការសាងសង់សមិទ្ធិដ៏វិសេសអស្ចារ្យមួយនេះ។



រូបភាព: www.lululoulou.over-blog.com



រូបភាព:www.voyages-conseils.com

ពីរ៉ាមិដដែលត្រូវបានឱ្យកសាងឡើងដោយ កេអុប ហ្វារ៉ាអុងនៅក្នុងអាណាចក្រទី ៤ (ក្នុងអំឡុងប្រហែលជា ២៨០០ ឆ្នាំ មុនគ្រិស្តសករាជ ប្រហែលជាមានកម្ពស់ពីដំបូងឡើយ ១៤៦ម៉ែត្រ ហើយមានទំហំ២៣៣ម៉ែត្រពីជ្រុងម្ខាងទៅជ្រុងម្ខាង។ សព្វថ្ងៃនេះពីរ៉ាមីដនេះត្រូវសឹករិចរិលខ្លាំងជាងពីរ៉ាមីដកេហ្វ្រែនដែលនៅក្បែរវា ហើយពីរ៉ាមីដកេហ្វ្រែននេះខ្ពស់ជាងពីរ៉ាមីដកេអុបតាំងពីដើមរៀងមក។ មនុស្សជំនាន់ដើមប្រសិទ្ធនាមពីរ៉ាមីដនេះថា អាគូអ៊ីដែលមានន័យថា ពន្លឺត្រចះត្រចង់ ក៏ព្រោះតែវាស្រោបដោយជាតិកាល់គែពណ៌សដែលភ្លឺចែងចាំងកាលពីសម័យនោះ តែជាអកុសលស្រទាប់ស្រោបវាត្រូវបានបាត់បង់ទៅហើយនាពេលសព្វថ្ងៃនេះ។ សំណង់មួយនេះធ្លាប់ត្រូវបានល្បីល្បាញមិនត្រឹមតែខាងរូបសម្រស់របស់វានោះទេ តែវាក៏ល្បីល្បាញដោយសារតែការតម្រង់ទិសដ៏ឥតល្អៀងរបស់វា និងដោយលក្ខណ:សនិទាន ព្រមទាំងលក្ខណ:ធរណីមាត្ររបស់វាផងដែរ។



រូបភាព:www.cheop.iframe.com

សើនអាឡិចសង់ឌ្រីត្រូវបានសាងសង់ឡើងនៅ Sostratos de Cnide ហើយយើងអាចស្គាល់សើននេះបានក៏ដោយសារតែសក្ខីកម្មអក្សរសិល្ប៍ (ក្នុងចំណោមសក្ខីកម្មទាំងនោះក៏មានស្នាដៃរបស់ Strabon et Lucien នៅសម័យមុនគ្រិស្តសករាជ និង Aboul Haggag នៅឆ្នាំ ១១៦៦) ដោយរូបិយវត្ថុមួយចំនួនតូចរបស់ពួករ៉ូម៉ាំង និងដោយរូបភាពផ្គុំដែលមានឈ្មោះថា "អាឡិចសង់ឌ្រីន" ។ ទោះជាបែបណាវាសមស្របណាស់ដែលត្រូវបញ្ចូលបន្ថែមនូវពែងអំពីកែវដ៏គួរឱ្យឆ្ងល់មួយដែលត្រូវបានរកឃើញនៅប៉ីហ្គ្រាមប្រទេសអាហ្គានីស្តង់ ដែលពែងនេះធ្វើឱ្យយើង នឹកស្រមើស្រមៃបានកាន់តែច្បាស់នូវរូបរាងរបស់សើនដ៏ល្បីល្បាញមួយនេះដែលប្រហែលជាសង់ឡើងដោយរួមមានជាច្រើនជាន់ និងលម្អដោយរូបចម្លាក់ធ្វើពីស្ពាន់ជាច្រើននៅតាមជ្រុងនានា និងនៅលើកំពូល។



រូបភាព : www.monmusee.canalblog.com

រូបចម្លាក់ Rhodes ដ៏ធំសម្បើមអស្ចារ្យ ក៏ត្រូវបានបាត់បង់ដែរ យើងគ្រាន់តែដឹងថាវាតំណាងឱ្យព្រះ Hélios ជាព្រះដែលអភិរក្សកោះ ហើយដែលរូបចម្លាក់មួយនេះជាស្នាដៃរបស់ជាងចម្លាក់ Charès de Lindos។



រូបភាព:www.virtuhall.com

អាឡិចសង់ និងទាហានរបស់ព្រះអង្គបានរកឃើញសួនច្បារអាកាសនៃទីក្រុងបាប៊ីឡូនដោយកោតស្ញប់ស្ញែងនៅពេលដែលពួកគេដើរកំសាន្តនៅអំឡុងឆ្នាំ ៣៣១ ដែលនៅពេលនោះទីក្រុងទើបតែត្រូវបានបំផ្លាញចោលទាំងស្រុង។ សមិទ្ធិផលដ៏ធំសម្បើមអស្ចារ្យនេះមិនមែនជារបស់ Sémiramis ដូចដែលបានអះអាងដោយប្រពៃណីក្រិកដែលច្រលំនោះទេ តែវាជាកម្មសិទ្ធិរបស់ Nabuchodonosor II (អំឡុងឆ្នាំ ៦០៤ ដល់ឆ្នាំ ៥៦២មុនគ្រិស្តសករាជ) ដែលបានបញ្ជាឱ្យសាងសង់សម្រាប់មហេសីរបស់ទ្រង់ព្រះនាម Amyitis ជាបុត្រីរបស់ Astyage ជាព្រះរាជានៃ Médie ដែលជារាជាណាចក្រមួយដែលមានព្រៃភ្នំ ដែលព្រះនាងនឹកអាឡោះអាល័យទៅដល់។



រូបភាព: www.afribone.com

ការរៀបរាប់របស់ Pausanias គឺជាជំនួយដ៏មានតម្លៃសម្រាប់យើងក្នុងការដឹងអំពីរូបចម្លាក់ Zeus ដែល Phidias បានឆ្លាក់ឡើងនៅ Olympie ក្នុងអំឡុងឆ្នាំ ៤៣២ ដល់ ៤៣១ មុនគ្រិស្តសករាជ។ ស្នាដៃនេះត្រូវបានស្ថាបនាឡើងដោយមាស នឹងភ្លុកដំរីនៅពីលើដែរណែងអំពីឈើ ហើយវាតំណាងឱ្យទេវៈអ្នូឡាំដ៏ល្បីឈ្មោះមួយអង្គដែលអង្គុយលើបល្ល័ងលម្អដោយរូបចម្លាក់តូចៗ និងរូបចម្លាក់លៀនយ៉ាងច្រើនមានដូចជា: ទេវៈរូបជ័យជំនះ រូបស្វាំង (ក្បាលមនុស្ស ខ្លួនជាតោ) ទេវៈរូបលើកលែងទោស ទេវរូបរដូវកាល។ ទេវៈអង្គឯងធ្វើពីភ្លុកលាបពណ៌ ចម្រុះ ទ្រង់គ្រងគ្រហស្តដ៏អស្ចារ្យដែលដេរយ៉ាងផ្ចិតផ្ចង់អំពីមាស ទ្រង់ប្រដាប់នៅក្នុងព្រះហស្តស្តាំទេវតំណាងឱ្យជ័យជំនះដែលធ្វើអំពីមាសនិងភ្លុកដំរីដែរ ហើយនៅព្រះហស្តឆ្វេងមានកាន់តំបងធ្វើពីមាស។ គ្រប់សមាសធាតុ រចនាបទព្រមទាំងចរិតលក្ខណៈនៃព្រះភ័ក្ត្រសុទ្ធសឹងបង្ហាញពីអំណាចនៃព្រះរាជា Zeus ដែលតំណាងឱ្យនូវជ័យជំនះយ៉ាងសម្បើមនៅក្នុងនាមជាអ្នកចម្បាំងក៏ដូចជាក្នុងនាមជាអ្នកអត្តពលកម្ម។




Zeus (undated drawing)

រូបភាព: www.pages-person.orange.fr

ជាចុងក្រោយគឺវិហារ Artémis នៅឯ phèse។ វិហារនេះត្រូវបានសាងសង់ឡើងនៅអំឡុងសតវត្សទី ៤ ក្រោយពីសំណង់ចាស់ត្រូវបានបំផ្លាញដោយព្រះអគ្គីនៅក្នុងអំឡុងឆ្នាំ ៣៥៦។ ស្ថាបត្យករឈ្មោះ Deinocratès។ ទំហំនៃការដ្ឋាននៅពេលកំពុងសាងសង់បានធ្វើឱ្យភ្ញាក់ផ្អើលដល់អាឡិចសង់នៅក្នុងពេលដែលទ្រង់ធ្វើដំណើរឆ្លងកាត់ទីនោះនៅក្នុងអំឡុងឆ្នាំ ៣៣៤ ហើយការទទួលស្គាល់ពីសំណង់មួយនេះក៏ត្រូវបានធ្វើឡើងភ្លាមៗ នាពេលនោះដែរ។



រូបភាព: www.his-nicolas.free.fr

បញ្ជីនៃអច្ឆរិយវត្ថុទាំង ៧នៅលើសកលលោកហាក់ដូចជាត្រូវបានកត់ត្រាបញ្ចូលបន្ថែមបន្តពីនោះមក ដោយហេតុថាអត្ថបទនានាបង្ហាញថាគេបានបញ្ចូលបន្ថែមបូជនីយដ្ឋានផ្សេងៗទៀតដែលនៅក្នុងនោះរួមមាន Asclepieion ព្រមទាំងខ្ទមដ៏ធំរបស់ Pergameផងដែរ។



រូបភាព: www.atheism.about.com

ប្រភព : *Encyclopædia Universalis 2004*

អត្ថបទ : សំអោ អង្គារតន៍